Little Tokyo Service Center

Adriana Perez:
213-481-0227
aperez@LTSC.org

LTSC មានវត្តមាននៅទីនេះដើម្បីជួយ

យើងដឹងថាមនុស្សជាច្រើនមានការព្រួយបារម្ភអំពីការរាយឆ្មក់ពីអាជ្ញាធរអន្តោប្រវេសន៍ និងការនិរទេស។ មជ្ឈមណ្ឌល *Little Tokyo Service Center (LTSC)* មានវត្តមាននៅទីនេះដើម្បីជួយគាំទ្រដល់លោកអ្នក។

អ្វីដែលយើងធ្វើ

LTSC ជួយនរណាម្នាក់ដែលមានភាពខ្វះខាត មិនថាអ្នកជាពលរដ្ឋឬអត់នោះទេ។ យើងមិនសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទើបផ្តល់សេវាកម្មដល់អ្នកនោះទេ។ ពេលខ្លះ យើងអាចនឹងត្រូវអនុវត្តតាមគោលនយោបាយរបស់រដ្ឋាភិបាលដែលដាក់កម្រិតទៅលើសេវាកម្មរបស់យើងដែលផ្តល់ជូនដល់ប្រជាពលរដ្ឋ ប៉ុន្តែវាកម្រនឹងមាន។

ព័ត៌មានរបស់អ្នកមានសុវត្ថិភាព

កផ្តល់មូលនិធិរបស់យើងតម្រូវឱ្យយើងប្រមូលព័ត៌មានមួយចំនួនដូចជាប្រាក់ចំណូល និងទំហំគ្រួសារ។

- យើងមិនដែលចែករំលែកព័ត៌មានរបស់អ្នកជាមួយអាជ្ញាធរអន្តោប្រវេសន៍ និងគយ (ICE) ឬអាជ្ញាធរល្បាតព្រំដែនឡើយ។
- ទីភ្នាក់ងាររដ្ឋាភិបាលដែលផ្តល់មូលនិធិដល់យើងក៏មិនអាចចែករំលែកព័ត៌មានរបស់អ្នកជាមួយ ICE ឬអាជ្ញាធរល្បាតព្រំដែនបានទេ។

សុវត្ថិភាពរបស់អ្នកគឺជាអាទិភាពទីមួយ

ផ្ទះរបស់អ្នក អគារ និងមត្តេយ្យសិក្សាគឺជាទ្រព្យសម្បត្តិឯកជន។

- អាជ្ញាធរ ICE ឬល្បាតព្រំដែន អាចចូលបានលុះត្រាតែពួកគេមានដីកាចុះហត្ថលេខាដោយចៅក្រម ហើយចៅក្រមនឹងតម្រូវឱ្យមានភស្តុតាងគ្រប់គ្រាន់អំពីឧក្រិដ្ឋកម្មមុនពេលចុះហត្ថលេខាលើដីកានោះ។
- យើងកំពុងបណ្តុះបណ្តាលបុគ្គលិក LTSC ដើម្បីធ្វើឱ្យប្រាកដថាត្រូវអនុវត្តតាមវិធានទាំងនេះ។
- យើងអាចផ្តល់ការបណ្តុះបណ្តាលអំពីការដឹងសិទ្ធិរបស់អ្នក (Know Your Rights) នៅអគាររបស់អ្នក។

ចំពោះជំនួយភ្លាមៗ ប្រសិនបើអ្នករងការរាយឆ្មក់ ឬអ្នកកំពុងត្រូវបានគេឃុំខ្លួន អ្នកអាចទាក់ទងមកកាន់៖

បណ្តាញឆ្លើយតបការរាយឆ្មក់នៅទីក្រុង Los Angeles លេខ 888-624-4752

យើងមានវត្តមាននៅទីនេះដើម្បីអ្នក

213-481-0227

LTSC យកចិត្តទុកដាក់ចំពោះសុវត្ថិភាព និងសុខុមាលភាពរបស់អ្នក។ សូមទាក់ទងមក ប្រសិនបើអ្នកត្រូវការជំនួយ។

- ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ត្រូវបានឃុំខ្លួន ឬរំខានដោយទីភ្នាក់ងារទាំងនេះ សូមប្រាប់យើងឱ្យដឹង។ យើងអាចភ្ជាប់អ្នកទៅកាន់មេធាវី និងជំនួយផ្សេងទៀត។
- សូមប្រុងប្រយ័ត្នចំពោះការបោកប្រាស់! មនុស្សមួយចំនួនអាចធ្វើពត់ជាភ្នាក់ងាររដ្ឋាភិបាល ឬសុំលុយដើម្បី "ដោះស្រាយ" បញ្ហាអន្តោប្រវេសន៍។ ប្រសិនបើមានអារម្មណ៍ថាមិនត្រឹមត្រូវ សូមទាក់ទងមកយើង។
- យើងផ្តល់ការគាំទ្រផ្នែកសុខភាពផ្លូវចិត្តសម្រាប់អគាររបស់អ្នក។ សូមអនុញ្ញាតឱ្យយើងដឹងប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម ឬត្រូវការឱ្យនរណាម្នាក់និយាយជាមួយ។